00195036

A/162/III/1

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ) |
| ដាក់ទៅ: | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់: | ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៨ |
| ភាគីអ្នកដាក់: | សហមេធាវីរបស់លោក អៀង សារី |
| ភាសាដើម: | អង់គ្លេស |
| ប្រភេទឯកសារ: | សាធារណៈ |

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06/06/2008
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

---

**បណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងសេចក្ដីសំរេចរបស់ ក.ស.ច.ស លើ**
***សំណើរបស់មេធាវីសុំព័ត៌មានទាក់ទងនឹងភាពលំអៀងដែលឃើញច្បាស់ និង***
***អត្ថិភាពដ៏មានសក្ដានុពលនៃទំនាស់ផលប្រយោជន៍នៃមន្ត្រីផ្នែកច្បាប់របស់ ក.ស.ច.ស.***
***ដេវិដ បយល៍** (David Boyle)*

---

**អ្នកដាក់ឯកសារ៖**

**សហមេធាវីរបស់លោក អៀង សារី**
លោក អាង ឧត្ដម
លោក Michael G. KARNAVAS

**អ្នកទទួលឯកសារ៖**

**អង្គបុរេជំនុំជម្រះ**
លោក ប្រាក់ គឹមសាន
លោក ន័យ ថុល
លោក ហួត វុទ្ធី
លោកស្រី Katinka LAHUIS
លោក Rowan DOWNING

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Robert PETIT

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 06/06/2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (ហៅថា "មេធាវីការពារ") យោងតាមវិធាន ៣៤(៥) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅថា "វិធានផ្ទៃក្នុង") ពេលនេះដាក់ប្ដឹងឧទ្ធរណ៍ជំទាស់នឹងលិខិតចេញដោយការិយាល័យសហចៅក្រមស៊ើបអង្កេត (ហៅថា "ក.ស.ច.ស") ចុះថ្ងៃទី ២៦ ឧសភា ឆ្នាំ ២០០៨[1] ច្រានចោលសំណើរបស់លោក **អៀង សារី** "សុំព័ត៏មានដែលទាក់ទងទៅនឹងភាពលំអៀងដែលឃើញច្បាស់ និង អត្ថិភាពដ៏មានសក្តានុពលនៃទំនាស់ផលប្រយោជន៏ទាក់ទងនឹងលោក **ដេវីដ បយល៍** (David Boyle)" ដែលបានដាក់ថ្ងៃទី ៤ មីនា ២០០៨ ("សំណើ") ។ មេធាវីការពារបានជូនដំណឹងដោយផ្ទាល់មាត់អំពីគោលបំណងប្ដឹងឧទ្ធរណ៍ជំទាស់នឹងសេចក្តីសំរេចនេះ នៅចំពោះមុខក្រឡាបញ្ជីរបស់ ក.ស.ច.ស កាលពីថ្ងៃទី ៥ មិថុនា ឆ្នាំ ២០០៨ តាមកាលកំណត់ដូចមានចែងក្នុងវិធាន ៧៥(១) ។

## I. សំណើសុំព័ត៌មានទាក់ទងនៅនឹងលោក ដេវីដ បយល៍

1. លោក អៀង សារី បានដាក់សំណើដើម្បីស្វែងរកព័ត៌មានទាក់ទងនឹងភាពសមស្របខាងវិជ្ជាជីវៈ និង ខាងក្រមសីលធម៏របស់មន្ត្រីផ្នែកច្បាប់[2]លោក **ដេវីដ បយល៍** ក្នុងការកាន់កាប់មុខងារបច្ចុប្បន្ននៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយពិចារណាថា ក.ស.ច.ស ដែលជាស្ថាប័នមួយឯករាជ្យរបស់ អ.វ.ត.ក[3] ត្រូវតែអនុវត្តកិច្ចស៊ើបសួររបស់ខ្លួនដោយអនាគតិ[4]។ ព័ត៌មានដែលស្វែងរក ក្នុងចំណោមបញ្ហាដទៃទៀត រួមបញ្ចូលនូវបញ្ជីនៃអត្ថបទទាំងអស់ដែលនិពន្ធដោយលោក **ដេវីដ បយល៍** ក៏ដូចជាសន្និសិទ វគ្គបណ្តុះបណ្តាល សវនាការ ការបង្ហាញបទឧទ្ទាសនាម សិក្ខាសាលា និង កិច្ចប្រជុំនានាទាក់ទងនឹង អ.វ.ត.ក ឬ ខ្មែរក្រហម ដែលលោក **ដេវីដ បយល៍** បានចូលរួម និងសេចក្តីពិពណ៌នាអំពីការចូលរួមរបស់លោក **ដេវីដ បយល៍** នៅក្នុងការព្រាងដីកាឃុំខ្លួនបណ្តោះ

---

[1] ករណីរបស់លោក អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស លិខិតមានចំណងជើងថា "សំណើសុំព័ត៏មានទាក់ទងនឹងភាពលំអៀងដែលឃើញច្បាស់ និង អត្ថិភាពដ៏មានសក្តានុពលនៃទំនាស់ផលប្រយោជន៏ទាក់ទងនឹងលោក MM S. Heder និង D.Boyle (ហៅថា "លិខិត") ។ មេធាវីការពារកត់សំគាល់ឃើញថា ទោះបីលិខិតនេះចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨ ក៏ដោយ តែវាត្រូវបានជូនដំណឹងមកមេធាវីការពារទើបតែថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៨ ប៉ុណ្ណោះ។ ដូច្នេះ កាលកំណត់យោងតាមវិធានផ្ទៃក្នុងនេះនឹងចាប់ផ្តើមរាប់ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

[2] មេធាវីមិនបានទទួលព័ត៏មាននូវមុខងារជាក់លាក់របស់លោក **ដេវីដ ប៊ីល** ទេ ប៉ុន្តែជឿជាក់ថាមុខងារនៃមន្ត្រីផ្នែកច្បាប់ គឺផ្ទុះបញ្ចាំងច្បាស់លាស់នូវតួនាទីចម្បងរបស់គាត់នៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត។ មេធាវីបានដឹងថាមុខងារផ្លូវការរបស់គាត់ប្រហែលជា "អ្នកស៊ើបអង្កេត ឬ អ្នកវិភាគ"។

[3] វិធាន ១៤ (១) នៃវិធានផ្ទៃក្នុង ។

[4] វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង ។

អាសន្ន និង ការពន្យល់ដែល ក.ស.ច.ស បានដឹងទាក់ទងនឹងតួនាទី និង អត្ថបទសរសេររបស់លោក **ដេវីដ បយល៍** នៅពេលជ្រើសរើសគាត់ឲ្យចូលបំរើការងារ។

2. ការព្រួយបារម្ភរបស់លោក **អៀង សារី** កើតចេញពីកត្តាដែលថាលោក **ដេវីដ បយល៍** មុនពេលចូលកាន់ការងារនៅ ក.ស.ច.ស បាននិពន្ធអត្ថបទជាច្រើនដែលទាក់ទងនឹង អ.វ.ត.ក និង ការកាត់ទោសខ្មែរក្រហមដែលគេរំពឹងថាធ្វើឡើង[5]។ នៅក្នុងបទអត្ថាធិប្បាយអំពី អ.វ.ត.ក ដែលរួមមានសុពលភាពនៃការអនុវត្តន៍ព្រះរាជក្រិត្យលើកលែង និង អនុគ្រោះទោសដល់លោក **អៀង សារី** លោក **ដេវីដ បយល៍** បានផ្តល់គំនិត និង ការសន្និដ្ឋានជាច្រើនដែលមានទំនងគួរឲ្យបារម្ភ ឆ្លុះបញ្ចាំងពីបុរេវិនិច្ឆ័យ និង ភាពលំអៀងប្រឆាំងលើលោក **អៀង សារី** ។ តាមរយៈភស្តុតាងដំបូងដៃ (*Prima facie)* នេះ ហាក់ដូចជាបង្ហាញថាលោក **ដេវីដ បយល៍** មិនមានគុណវុឌ្ឍិដើម្បីទទួលតួនាទីណាមួយនៅក្នុង ក.ស.ច.ស. បានឡើយ។

3. ឧទាហរណ៏ លោក **ដេវីដ បយល៍** បានថ្លែងថា៖

> ករណីរបស់លោក **អៀង សារី** គឺជាឧទាហរណ៍មួយនៃបណ្តាបញ្ហាដែលនឹងកើតឡើងនៅចំពោះមុខតុលាការកម្ពុជា។ លោក **អៀង សារី** ត្រូវបានលើកលែងទោស ដែលមានសុពលភាពតាមច្បាប់រដ្ឋធម្មនុញ្ញ និង អភ័យឯកសិទ្ធិចំពោះបទល្មើសមួយចំនួន និង ការកាត់ទោសតាមច្បាប់ឆ្នាំ ១៩៩៤។ តើការលើកលែងទោស និង ការអនុគ្រោះទោសដែលមានសុពលភាពតាមច្បាប់រដ្ឋធម្មនុញ្ញនេះ អាចអនុវត្តនៅចំពោះមុខសាលាក្តីខ្មែរក្រហមនេះបានក្នុងកម្រិតណា? ចំណុចនេះទុកឲ្យតុលាការសម្រេច។ បញ្ហាទាំងអស់នេះនឹងលើកឡើងដោយមេធាវីការពារ *ហើយគួរតែដោះស្រាយជាមុន ដើម្បីបញ្ចៀសការពន្យឺតសវនាការដោយមេធាវីការពារក្តីដែលប៉ិនប្រសប់ បើមិនដូច្នេះទេ ដំណើរការកាត់ក្តីរយៈពេលបីឆ្នាំនឹងមិនអាចបញ្ចប់បានឡើយ។ មានលទ្ធភាពពីរដើម្បីដោះស្រាយបញ្ហាទាំងនេះបានមួយចំណែក។ លទ្ធភាពទីមួយ គឺថាចៅក្រម បន្ទាប់ពីបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវជួបពិភាក្សាជាមួយព្រះរាជអាជ្ញា និង ចៅក្រមស៊ើបអង្កេតជាបន្ទាន់ ដើម្បីរិះរកនីតិវិធីពិតប្រាកដបែបណាដែលអាចឲ្យតុលាការ*

5 សូមមើល ឧបសម្ព័ន្ធ ១ ដែលមានបញ្ជីរាយនាមអត្ថបទជាច្រើនដែលក្រុមមេធាវីការពារលោក អៀង សារី បានដឹង។ ដោយហេតុថា ការលំអៀងរបស់លោក **ដេវីដ បយល៏** ក្នុងការអត្ថាធិប្បាយអំពី អ.វ.ត.ក និងអំពីការអនុវត្តច្បាប់និងនីតិវិធីផ្សេងៗ គេមិនអាចដឹងបានថាតើបញ្ជីនេះមានរាយដាក់បញ្ចូលនូវអត្ថបទ ឬ សំណៅសរសេរទាំងអស់ដែលបានធ្វើឡើងដោយលោក **ដេវីដ បយល៏** ដែរឬក៏អត់

*អនុវត្តបាន។ ចៅក្រមមិនអាចផ្លាស់ប្តូរច្បាប់បានទេ ប៉ុន្តែ ពួកគេអាចពិចារណាថាតើច្បាប់មានន័យយ៉ាងដូចម្តេច*[6] ។

4. សេចក្តីថ្លែងនេះបង្ហាញយ៉ាងច្បាស់នូវជំនឿទៅកាន់ផ្លូវខុសរបស់លោក **ដេវីដ បយល៍** ដែលថាមេធាវីការពារគួរត្រូវតែបានហាមឃាត់មិនឱ្យជួយតុលាការក្នុងការកំណត់លើបញ្ហាណាក្តីទាក់ទងនឹងការលើកលែងទោសនិងអនុគ្រោះទោសដែលមានសុពលភាពតាមច្បាប់រដ្ឋធម្មនុញ្ញរបស់លោក **អៀង សារី** ។ គាត់មិនត្រឹមតែបានថ្លែងបញ្ចិតបញ្ចៀងថា មេធាវីការពារនឹងគ្មានអ្វីដើម្បីជួយរួមចំណែកទេ ហើយនឹងព្យាយាមបន្ទុចបង្អាក់ដំណើរការរឿងក្តីទៅវិញតែប៉ុណ្ណោះ តែគាត់ថែមទាំងបានបន្តទៅជួយគាំទ្រដល់នីតិវិធី *Star Chamber* ជាវិធីដែលមានតែភាគីម្ខាង *(Ex parte)* ដែលចៅក្រម ព្រមជាមួយការិយាល័យសហព្រះរាជអាជ្ញា (ភាគីមួយ) និង ក.ស.ច.ស. (ដោយអះអាងថាជាស្ថាប័នអនាគតិចំពោះដំណើរការរឿងក្តី) ដើម្បីដោះស្រាយបញ្ហាដោយលបលាក់ មុនមេធាវីការពារមានពេលវេលាធ្វើប្រតិកម្មតប។ តាមពិត ការសន្និដ្ឋានរបស់លោក **ដេវីដ បយល៍** ដែលថាបញ្ហាត្រូវតែបានដោះស្រាយមុនមេធាវីការពារមានឱកាស"ពន្យឺតសវនាការ" មានទំនងហាក់ដូចជាចង់ពន្យល់ពីហេតុដែល ក.ស.ច.ស. បានសម្រេចតាមឆន្ទះឯកឯង (*Proprio Motu*) របស់ខ្លួនដើម្បីលើកបញ្ហា *ne bis in idem* (គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ) និងការលើកលែងទោស និង អនុគ្រោះទោសនៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ។

5. ដោយសារលោក **ដេវីដ បយល៍** មិនមែនជាចៅក្រម នោះមុខងារធម្មតារបស់គាត់គឺត្រូវផ្តល់សំអាងហេតុនិងមតិយោបល់តាមផ្លូវច្បាប់ជាសត្យានុម័ត និង ដែលមិនលំអៀងដល់ ក.ស.ច.ស. ដែលត្រូវបានផ្តាក់ផ្ទុកឱ្យធ្វើការយល់ឃើញលើអង្គហេតុនិងសន្និដ្ឋានលើអង្គច្បាប់[7]។ អ្នកទាំងឡាយណា

---

[6] របាយការណ៍ដែលបានពីសិក្ខាសាលាមួយ ធ្វើឡើងនៅទីក្រុងភ្នំពេញ ចាប់ពីថ្ងៃទី២ ដល់ ៣ ខែមីនា ឆ្នាំ២០០៥ រៀបចំដោយ FIDH-LICADHO-ADHOC និង កម្មវិធីតុលាការព្រហ្មទណ្ឌអន្តរជាតិ ក្រោមប្រធានបទ: ភាពស្របគ្នារវាងតុលាការព្រហ្មទណ្ឌអន្តរជាតិនិងសាលាក្តីខ្មែរក្រហម: ទីកន្លែងរបស់ជនរងគ្រោះ និង ក្របខណ្ឌច្បាប់របស់សាលាក្តីខ្មែរក្រហម ទំព័រ ១៨ (បញ្ជាក់បន្ថែម) អាចរកបាននៅគេហទំព័រ: http:www.vrwg.org/Publications/02/FIDHcambodge420ang.pdf.

[7] អនុលោមទៅតាមលក្ខខណ្ឌការងាររបស់ពួកគេ ក៏ដូចជាលក្ខខណ្ឌការងាររបស់ជំនួយការច្បាប់ផងដែរ ពួកគេមានតួនាទីជួយគាំទ្រដល់ "ការវាយតម្លៃនៃបទចោទប្រកាន់ដែលបានលើកឡើង ព្រមទាំងភស្តុតាងដែលដាក់ដោយភាគី និង វាយតម្លៃលើសេចក្តីត្រូវការសម្រាប់កិច្ចស៊ើបអង្កេតបន្ថែម ផ្តល់យោបល់ដល់សហចៅក្រមស៊ើបអង្កេតស្តីពីបទចោទប្រកាន់ណាមួយ ... និង ផ្តល់ការប្រឹក្សាផ្នែកច្បាប់ទៅសហចៅក្រមស៊ើបអង្កេត អ្នកស៊ើបអង្កេត និង អ្នកវិភាគ ទៅលើច្បាប់ និង នីតិវិធីព្រហ្មទណ្ឌកម្ពុជា និង អន្តរជាតិដែលនៅជាធរមាន និង បញ្ហាច្បាប់ផ្សេងៗទៀតដែលកើតឡើង"។ ពួកគេក៏ជួយគាំទ្រការផ្តល់ការឆ្លើយតបសមស្របរបស់តុលាការឲ្យទាន់ពេលវេលាទៅនឹងសំណើ និង ពាក្យសុំដែលដាក់តម្កល់ដោយភាគីពាក់ព័ន្ធតាមរយៈការស្រាវជ្រាវទៅលើ ច្បាប់ និង នីតិវិធីព្រហ្មទណ្ឌកម្ពុជា និង អន្តរជាតិ បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និង បញ្ហា

ដែលជួយចៅក្រមតាមរបៀបនេះគឺ "ជាក្រុមប្រឹក្សាយោបល់សម្រាប់ផ្តល់មតិសាកល្បង និង ជាអ្នកស្រាវជ្រាវស្វែងរកកម្រងយុត្តិក្រមទាំងឡាយ ដែលមានអនុភាពលើសេចក្តីសម្រេចនានា។ លេខាធិការ (ក្រឡាបញ្ជី) មានលក្ខណៈសម្ងាត់ចំពោះគំនិតរបស់ចៅក្រម តាមរបៀបនេះ មិនអាចជាភាគីនៃរឿងក្តី ឬ ជាសមាជិកគ្រួសារជិតស្និទរបស់ចៅក្រមបានឡើយ[8]។ ជាផលវិបាក "ទោះបីចៅក្រមមិនមានមូលហេតុដើម្បីបង្ខូចគុណវុឌ្ឍិខ្លួនឯង ដោយផ្អែកតាមកាលៈទេសៈផ្ទាល់ខ្លួនក្តី ក៏ទំនាក់ទំនងរបស់លេខាធិការតុលាការ អាចបង្កឲ្យមានភាពឥតលំអៀងនៃសេចក្តីសម្រេចដែលកើតចេញពីចៅក្រមនៃអង្គជំនុំជម្រះដែលលេខាធិការតុលាការរូបនោះចូលរួម សមនឹងចោទជាបញ្ហាពុំខានឡើយ[9]"។ ហេតុដូច្នេះ ខណៈជាអ្នកចាំវិភាគផ្នែកច្បាប់និងក្នុងនាមជាអ្នកផ្តល់សំអាងហេតុដល់សហចៅក្រមស៊ើបអង្កេត មន្ត្រីផ្នែកច្បាប់គួរមានមន្ទិលសង្ស័យរៀបរាប់ដូចខាងលើ[10]។

6. ដោយសារតែការផ្តល់មតិនិងការប្រកាសជាសាធារណៈយ៉ាងទូលំទូលាយរបស់លោក **ដេវីដ បយល៍** ទៅលើបញ្ហាទាក់ទងទៅនឹង អ.វ.ត.ក និងជាពិសេស ទាក់ទងទៅនឹងលោក **អៀង សារី** លោក **ដេវីដ បយល៍** គឺមិនផុតពីការសង្ស័យទេ។ ហេតុដូច្នេះ ដើម្បីកំណត់ឲ្យបានរឹតតែពេញលេញ

---

ច្បាប់ដ៏ទៃទៀតដែលបានកើតឡើង"លក្ខខណ្ឌការងាររបស់ជំនួយការច្បាប់អាចរកបាននៅលើគេហទំព័រ៖ https://jobs.un.org/Galaxy/Release3/vacancy/Display_Vac.aspx?lang=1200&VACID=43216be8-2388-48ab-b66c-01f68b42b0af.

8 *Hall តទល់នឹង Small Business Administration,* 695 F.2d 175, 179 (5th Cir. 1983)

9 *Hamid តទល់នឹង Price Waterhouse,* 51 F.3d 1411, 1416-17 (9th Cir. 1995); ដោយសំអាងលើផលប៉ះពាល់ដល់ភាពមិនលំអៀងដោយមន្ត្រីម្នាក់ក្នុងចំណោមមន្ត្រីផ្នែកច្បាប់ដែលធ្វើការក្នុង ក.ស.ច.ស មាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា ផ្តល់នូវអាណត្តិដល់តុលាការមួយដែលឯករាជ្យ និង អនាគតិ ឆ្លុះបញ្ចាំងនៅក្នុងកិច្ចព្រមព្រៀង និងច្បាប់ ដែលចែងថាចៅក្រម អ.វ.ត.ក ទាំងអស់ "ត្រូវតែឯករាជ្យនៅក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនត្រូវទទួលយក ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬប្រភពណាមួយផ្សេងទៀតឡើយ" (សូមអានមាត្រា ៣(៣) នៃកិច្ចព្រមព្រៀង និងមាត្រា ១០ថ្មីនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)។ សំខាន់ជាងនេះទៅទៀត ការធានាតាមផ្លូវតុលាការដែលមានចែងនៅក្នុងមាត្រា១៤(១) នៃ ICCPR មាត្រា៦(១) នៃអនុសញ្ញាសហភាពអឺរ៉ុបស្តីពីសិទ្ធិមនុស្ស មាត្រា៨ នៃអនុសញ្ញាអាមេរិកកាំងស្តីពីសិទ្ធិមនុស្ស និងមាត្រា៨(១) នៃធម្មនុញ្ញ[Banjul]ទ្វីបអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាពលរដ្ឋ។ ជាការពិតគណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប បានថ្លែងថា ការធានាឯករាជ្យភាព និងអនាគតិ "គឺជាសិទ្ធិដាច់ខាតដែលមិនត្រូវទទួលបាននូវការលើកលែងណាមួយបានឡើយ" (សូមមើល Gonzalez del Rio v. ប្រទេសប៉េរូ Communication លេខ ២៦៣/១៩៨៧ ឯកសារ អ.ស.ប CCPR/C/៤៦/D/២៦៣/១៩៨៧ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩២)។ ដោយសារថា ទស្សនៈនៃឯករាជ្យភាព និងអនាគតិមានទំនាក់ទំនងគ្នាជិតស្និទ្ធ វាជាការសមស្របបំផុតក្នុងការពិចារណាចំនុចទាំងពីរ នេះរួមគ្នា (សូមមើល Jessica Simor និង Ben Emmerson QC ការអនុវត្តន៍សិទ្ធិមនុស្ស (Sweet និង Maxwell ២០០៦) (Simor និង Emmerson) § ៦.១២០)

10 Leeson v. ក្រុមប្រឹក្សាភិបាលវេជ្ជសាស្ត្រយទូទៅ (១៨៨៩) ៥៩ LJChNS ២៣៣ នៅទំព័រ ២៤១ ។

ថាតើ មេធាវីការពារគួរបន្តស្នើសុំឲ្យដកហូតលោក **ដេវីដ បយល៍** ចេញឬយ៉ាងណានោះ មេធាវីការពារបានដាក់ជូនសំណើនេះដោយក្តីគោរពទៅ ក.ស.ច.ស រួចហើយ ។

7. ក.ស.ច.ស បានឆ្លើយតបសំណើរបស់មេធាវីការពារនៅថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០០៧ ។ នៅក្នុងសារលិខិតនោះ ក.ស.ច.ស បានអះអាងថា "ហាក់ដូចជាមិនមានមូលដ្ឋានច្បាប់ណាមួយសម្រាប់ការទាមទារច្រំដែលបែបនោះទេ"។ ក.ស.ច.ស បានពិចារណាថា "បន្ទាប់ពីមានការស្រាយបំភ្លឺនេះទៅ យើងមិនបានមើលឃើញមានហេតុផលណាមួយដើម្បីបន្តការឆ្លើយតបទៀតទេ ហើយចំពោះពួកយើង លិខិតនេះគឺជាសារចុងក្រោយទាក់ទងនឹងបញ្ហានេះ"។ ដោយការគោរពចំពោះ ក.ស.ច.ស លិខតនេះបង្ហាញទាំងការយល់ច្រឡំទៅលើសំណើ ទាំងការបដិសេធដែលព្រួយបារម្ភក្នុងការផ្តល់ព័ត៌មានដែលបានស្នើសុំ។ លិខិតនេះហាក់ដូចជាដាក់ច្រវាក់គាបឆន្ទានុសិទ្ធរបស់ ក.ស.ច.ស ក្នុងការបង្ការជាមុននូវការប៉ុនប៉ងណាមួយនាពេលអនាគតដោយមេធាវីការពារ ដើម្បីកែតម្រូវការយល់ច្រឡំនេះ។ លិខិតនេះក៏បានបដិសេធទុកជាមុននូវការប៉ុនប៉ងដកហូតតួនាទីលោក **ដេវីដ បយល៍** នាពេលអនាគតគផងដែរ។ ហេតុដូច្នេះហើយ មេធាវីការពារមានកាតព្វកិច្ចប្តឹងឧទ្ធរណ៍នឹងសេចក្តីសំរេចនេះជាជាងស្វះស្វែងរកសេចក្តីបញ្ជាក់លើសំណើរបស់ខ្លួនពី ក.ស.ច.ស។

8. សូមកត់សំគាល់ថា សំណើដើមដំបូងគឺដើម្បីសុំ"ព័ត៌មាន"បន្ថែម និងមិនមែនសុំដកហូតតួនាទីរបស់លោក **ដេវីដ បយល៍** នោះទេ។ សម្រាប់ឲ្យមេធាវីការពារមានលទ្ធភាពសមរម្យក្នុងការសម្រេចឲ្យបានត្រឹមត្រូវថាតើត្រូវស្វែងរកការដកហូតតួនាទីរបស់លោក **ដេវីដ បយល៍** ឬ យ៉ាងណានោះ មេធាវីការពារក្តីបានពិចារណាថា ព័ត៌មានជាក់លាក់ដែលកាន់កាប់និងគ្រប់គ្រងដោយ ក.ស.ច.ស ត្រូវតែបានពិនិត្យ។ អាស្រ័យហេតុនេះ លិខិតនោះអាចឬគួរត្រូវបានដាក់កម្រិតដើម្បីយល់ព្រមតាមសំណើ ឬ បដិសេធសំណើ។ ជាជាងនេះ ក.ស.ច.ស តាមអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន (*proprio motu)* ហាក់ដូចជាបានសម្រេចលើបញ្ហាថាក្រៅពីសហចៅក្រមស៊ើបអង្កេតខ្លួនឯង អាចរងការដកហូតមុខតំណែង។ សេចក្តីសម្រេចនេះហាក់ដូចជាកើតចេញពីការយល់ច្រឡំទៅលើសំណើ។

9. ឧទាហរណ៍ទីមួយ ដែលកើតចេញពីការយល់ច្រឡំនេះ គឺថាលិខិតនេះបានអះអាងថា "វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. មិនបានចែងថាភាគីណាអាចស្នើសុំដកហូតតួនាទីរបស់អ្នកស៊ើបអង្កេត"។ ទីពីរ លិខិតបានរំលឹកថា ការប្តឹងជិតចិត្តចំពោះចៅក្រមណាម្នាក់ "ត្រូវអនុវត្តតាមនីតិវិធីជាក់លាក់ [...] ជាពិសេស ភស្តុតាងគាំទ្រដល់បណ្តឹងជិតចិត្តត្រូវផ្តល់ដោយភាគី មិនមែនដោយចៅក្រមដែលរងបណ្តឹងជិតចិត្តនោះទេ"។ នៅក្នុងអះអាងបែបនេះ ក.ស.ច.ស ហាក់ដូចជាជឿជាក់ថា សំណើនេះ

គឺជាសំណើសុំដកហូតតួនាទីរបស់លោក **ដេវីដ បយល៍** ហើយថា មេធាវីមិនបានផ្តល់ភស្តុតាងចាំបាច់ដើម្បីគាំទ្រដល់សំណើបែបនេះទេ។

10. ដោយហាក់ដូចជាចង់ដោះស្រាយមុនកាលកំណត់នូវបញ្ហាចម្បងថាតើលោក **ដេវីដ បយល៍** គួរត្រូវបានដកហូតពីមុខតំណែងឬយ៉ាងណានោះ និង ដើម្បីច្រានចោលបញ្ហាដែលជំពក់ទាក់ទិននៅចំពោះខ្លួន លិខិតនេះបង្កឲ្យមានការព្រួយបារម្ភថែមទៀតទាក់ទងនឹងអនាគតិរបស់លោក **ដេវីដ បយល៍** ។ វាបង្កើតជាការយល់ឃើញមិនត្រឹមត្រូវថា ក.ស.ច.ស មានអ្វីមួយលាក់ទុក ដោយការបដិសេធមិនផ្តល់ព័ត៌មានដែលបានស្នើសុំ។

11. បន្ថែមពីលើនេះ តាមការអះអាងដែលថាវាជាភារកិច្ចរបស់ភាគីដាក់សំណើដែលត្រូវផ្តល់ព័ត៌មាន "មិនមែនចៅក្រមពាក់ព័ន្ធត្រូវផ្តល់ព័ត៌មាននោះឡើយ" លិខិតនេះពិតជាធ្វើឲ្យមេធាវីការពារស្ថិតក្នុងជំហរមួយមិនអាចធ្វើអ្វីបាន។ ប្រសិនបើព័ត៌មានដែលបានស្នើសុំស្ថិតនៅក្រោមគ្រប់គ្រងរបស់ ក.ស.ច.ស ដូចនៅក្នុងករណីនេះអញ្ចឹង គឺមានតែតាមការស្នើសុំនិងការប្រគល់ឲ្យព័ត៌មាននោះប៉ុណ្ណោះ ដូចមេធាវីការពារបានកំពុងស្វែងរកនៅក្នុងករណីនេះ ដែលសំណើពេលក្រោយៗមកទៀតសុំដកហូតមុខតំណែងណា អាចមានការគាំទ្រត្រឹមត្រូវ។ ប្រសិនបើ ក.ស.ច.ស សម្រេចច្រានសំណើចោលងាយៗបែបនេះ ខណៈព័ត៌មានពាក់ព័ន្ធកំពុងគ្រប់គ្រងដោយការិយាល័យនេះ នោះសំណើសុំដកហូតមុខតំណែងណាមួយនាថ្ងៃអនាគតនឹងមិនសម្រេចដូចបំណងឡើយ។ នេះមិនដែលជាក្តីបំណងប្រាថ្នារបស់វិធានផ្ទៃក្នុងដែលស្វែងរកការធានា "ភាពសមស្របតាមបទដ្ឋានអន្តរជាតិ" អនុលោមទៅបុព្វកថារបស់វិធាននេះឡើយ។ ជាអវសាន សូមរំលឹកថា នៅពេលមានបណ្តឹងជំទាស់ជាអាទិ៍ដែលបានធ្វើឡើងដោយភាគីមួយផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក.[11]ចៅក្រមសាម៉ីបានផ្តល់ព័ត៌មានតាមការស្នើសុំ ដោយឈរលើស្មារតីស្មោះត្រង់ និង តម្លាភាព[12] ។

## II ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

12. មេធាវីការពារស្នើថា បណ្តឹងឧទ្ធរណ៍ទៅលើលិខិតនេះ ត្រូវតែធ្វើឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះ។ តាមវិធានផ្ទៃក្នុង ៣៤(៥) "ពាក្យបណ្តឹងជំទាស់ចំពោះសហចៅក្រមស៊ើបអង្កេត ត្រូវដាក់ជូនទៅអង្គជំនុំជម្រះវិសាមញ្ញ"។ បទបញ្ញត្តិនេះមិនមែនត្រឹមតែជាសិទ្ធិទេ ប៉ុន្តែជាការបង្គាប់បញ្ជា

---

11 ករណី នួន ជា សំណុំរឿងលេខ 002/19-09-2007-អ.វ.ត.ក/អ.ប.ជ(០៦) សំណើជាបន្ទាន់ស្នើសុំប្តឹងជំទាស់ចៅក្រម ន័យ ថុល ថ្ងៃទី២៨ ខែកុម្ភៈ ២០០៨ ។

12 ករណី នួន ជា សំណុំរឿងលេខ 002/19-09-2007-អ.វ.ត.ក/អ.ប.ជ(០៦) សារណារបស់ចៅក្រម ន័យ ថុល ឆ្លើយតបនឹងបណ្តឹងជំទាស់ពីសហមេធាវី នួន ជា ចុះថ្ងៃទី២៨ និង៣១ ខែមករា ឆ្នាំ២០០៨ ។

អោយមេធាវីការពារដាក់បណ្តឹងជំទាស់ណាមួយនៅចំពោះមុខអង្គបុរេជំនុំជម្រះ។ មិនមានភាពច្បាស់លាស់ថាតើសំណើសុំនេះ ជាបឋម អាចដាក់ប្តឹងនៅចំពោះមុខ ក.ស.ច.ស ហើយសឹមដាក់ប្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ ឬមួយក៏ប្តឹងទៅចំពោះមុខអង្គបុរេជំនុំជម្រះតែម្តងជាដំណាក់កាលជាន់ដំបូង (at first instance)។ ករណីណាមួយក្នុងចំណោមករណីទាំងពីរនេះ បើវាជាបណ្តឹងឧទ្ធរណ៍ ឬ សំណើសុំដំណាក់កាលជាន់ដំបូង (at first instance) ក៏ដោយក៏មេធាវីការពារដាក់ស្នើថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន។

13. ទោះបីជាសំណើសុំនេះត្រឹមតែព័ត៌មាន ជាជាងសំណើសុំប្តឹងជំទាស់ដ៏ពិតប្រាកដនោះ ការពិតគឺថាព័ត៌មានដែលស្នើសុំនោះ តម្រូវជា “ភស្តុតាងគាំទ្រ” សំរាប់ការប្តឹងជំទាស់នៅពេលក្រោយមកតាមវិធាន ៣៤(៣) ដែលផ្សាភ្ជាប់ដោយផ្ទាល់នូវសំណើសុំព័ត៌មាននេះទៅនឹងពាក្យសុំប្តឹងជំទាស់។ ជាការមិនសមហេតុផលទាំងស្រុង ដែលតម្រូវអោយសំណើសុំប្តឹងជំទាស់សហចៅក្រមស៊ើបអង្កេតត្រូវធ្វើនៅចំពោះមុខអង្គបុរេជំនុំជម្រះ ប៉ុន្តែមិនអនុញ្ញាតអោយសំណើសុំនូវព័ត៌មានដើម្បីគាំទ្រដល់ការប្តឹងជំទាស់បែបនោះធ្វើនៅចំពោះមុខអង្គបុរេជំនុំជម្រះតែមួយដដែលនោះ។

14. ជាងនេះទៅទៀត ដូចដែលបានពន្យល់ខាងលើមក ក.ស.ច.ស ទំនងជាបកស្រាយសំណើសុំថាជាការស្វែងរកការប្តឹងជំទាស់ជាជាងការស្វែងរកព័ត៌មានបន្ថែមប៉ុណ្ណោះ ដែលតាមន័យនេះ ប្រគល់សិទ្ធិដល់មេធាវីការពារប្តឹងផ្ទាល់ទៅកាន់អង្គបុរេជំនុំជម្រះ។ ចុងបញ្ចប់ ទោះបីជាសំណើសុំទាក់ទងទៅនឹងភាពលំអៀងដែលឃើញច្បាស់ និង អត្ថិភាពដ៏មានសក្តានុពលនៃទំនាស់ផលប្រយោជន៍ទាក់ទងនឹងមន្ត្រីផ្នែកច្បាប់ ជាជាងសហចៅក្រមស៊ើបអង្កេតខ្លួនឯង យុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ស្នើថា ពាក្យស្នើសុំទាំងឡាយទាក់ទងករណីទីមួយ (មន្ត្រីផ្នែកច្បាប់) ត្រូវតែសំរេចទៅតាមបទបញ្ញត្តិដែលទាក់ទងនឹងករណីទីពីរដែរ (ចៅក្រម)[13] ។

---

[13] *សូមមើល ករណីរដ្ឋអាជ្ញា តទល់នឹងThomas Lubanga Dyilo* សំណុំរឿងលេខ៖ ICC-0១/0៤-0១/0៦ សេចក្តីសំរេចចុះថ្ងៃទី ២៧ តុលា ២00៦ លើសំណើរបស់រដ្ឋអាជ្ញាសុំបំបែកទីប្រឹក្សាច្បាប់ជាន់ខ្ពស់របស់អង្គបុរេជំនុំជម្រះចេញពីការផ្តល់នូវឱវាទផ្នែកច្បាប់ដែលទាក់ទងនឹងរឿងក្តី។ អង្គបុរេជំនុំជម្រះបានពិចារណាថា សំណើរបស់រដ្ឋអាជ្ញាដើម្បីរាំងមន្ត្រីផ្នែកច្បាប់ជាន់ខ្ពស់ពីការផ្តល់ឱវាទក្នុងរឿងក្តី *Lubanga* “ប្រហែលដូចគ្នានឹងសំណើសុំប្តឹងជំទាស់ចៅក្រម ឬ យ៉ាងហោចបំផុតក៏ប្រហែលជាលើកឡើងនូវបញ្ហាទាក់ទងនឹងការប្តឹងជំទាស់ចៅក្រម ដែលឋិតនៅក្រោមវិសាលភាពនៃមាត្រា ៤១(២) នៃច្បាប់លក្ខន្តិកៈ” នៅទំព័រទី២។ ជាវិបាក សំណើសុំត្រូវបានបញ្ជូនទៅការប្រជុំពេញអង្គរបស់ចៅក្រមដែលជួបប្រជុំគ្នាតាមមាត្រា ៤១(២(គ)។ វាមានសារៈសំខាន់គួរកត់សំគាល់ថា សំណើសុំរបស់រដ្ឋអាជ្ញាគឺជាការសុំបំបែកចេញពីគ្នា ឬ ការប្តឹងជំទាស់មន្ត្រីច្បាប់ជាន់ខ្ពស់ និងមិនមែនជាចៅក្រមទេ ប៉ុន្តែតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) នៅតែយកតាមនីតិវិធីដែលចែងអំពីការប្តឹងជំទាស់ចៅក្រម។ មានតែចៅក្រមទេ ដែលគេសំដៅទៅក្នុងមាត្រា ៤១។

15. ប្រសិនបើលោក **ដេវីដ បយល៍** ពិតជាបង្កនូវភាពលំអៀងមែន ការលំអៀងនេះនឹងធ្វើឲ្យប៉ះពាល់ខូចដល់សេចក្តីសម្រេចនាពេលអនាគតរបស់ ក.ស.ច.ស ពាក់ព័ន្ធទៅនឹងលោក **អៀង សារី**។ ដូច្នោះ ជាការចាំបាច់ដែលបញ្ហានេះត្រូវតែបានលើកមកដោះស្រាយជាបន្ទាន់ ប្រកបដោយតម្លាភាព និងភាពត្រឹមត្រូវ។ យុត្តិធម៌មិនគ្រាន់តែធ្វើបានសម្រេចនោះទេ ប៉ុន្តែយុត្តិធម៌ត្រូវតែធ្វើឲ្យគេឃើញថាមាន ដោយគ្មានមន្ទិលសង្ស័យ។ តាមការថ្លែងម៉ាត់ៗថា "ចំពោះពួកយើង លិខិតនេះគឺជាសារចុងក្រោយទាក់ទងនឹងបញ្ហានេះ" លិខិតនេះបញ្ជាក់ថាការឆ្លើយឆ្លងលើកក្រោយរវាងមេធាវីការពារជាមួយ ក.ស.ច.ស នឹងមិនទទួលបានការឆ្លើយតបឡើយ។ វាហាក់ដូចជាថា ការប៉ុនប៉ងនាថ្ងៃអនាគតរបស់មេធាវីការពារដើម្បីដកហូតមុខតំណែងរបស់លោក **ដេវីដ បយល៍** ឬ មន្ត្រីណាម្នាក់ដែលបំរើការងារឲ្យ ក.ស.ច.ស ដែលមិនមែនជាសហចៅក្រមស៊ើបអង្កេតណាម្នាក់ខ្លួនឯង នឹងត្រូវបានបដិសេធភ្លាមៗ តាមរយៈការបដិសេធមិនពិចារណាសំណើណាមួយលើកក្រោយៗទាក់ទងនឹងបញ្ហានេះ។ ដោយហេតុនេះ ការចូលអន្តរគមន៍ពីសំណាក់អង្គបុរេជំនុំជម្រះនៅដំណាក់កាលនេះគឺពិតជាចាំបាច់ ។

## III. សេចក្តីសន្និដ្ឋាន និង ការស្នើសុំដំណោះស្រាយ

អាស្រ័យដោយហេតុផលទាំងអស់ដូចមានបញ្ជាក់ជូននៅទីនេះ មេធាវីការពារស្នើដោយក្តីគោរព សុំអង្គបុរេជំនុំជម្រះមេត្តាលុបចោលសេចក្តីសំរេចរបស់ ក.ស.ច.ស និង បង្ខំអោយបញ្ចេញនូវព័ត៌មានដែលបានស្នើសុំ។

សូមអង្គបុរេជំនុំជម្រះទទួលសំណើសុំនេះដោយក្តីគោរព។

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៨